លេខ ២៤ ចេញផ្សាយថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែឧសភា ឆ្នាំ២០២៣

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## សិក្ខាសាលាស្តីពី "បទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ចនៅកម្ពុជា៖ ទស្សនទានពីនិយ័តករបរធនបាលកិច្ច"

នាព្រឹកថ្ងៃអង្គារ ១៣កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមជាមួយ **ឯកឧត្តម** Datuk Eldeen Husaini Mohd Hashim ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំកម្ពុជា និង **ឧកញ៉ា** Tan Khee Meng ប្រធានសភាពាណិជ្ជកម្មម៉ាឡេស៊ីប្រចាំនៅកម្ពុជា ជាអធិបតីដ៏ខ្ពង់ខ្ពស់ និងដើម្បីបើកកម្មវិធីសិក្ខាសាលាស្តីពី "បទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ចនៅកម្ពុជា៖ ទស្សនទានពីនិយ័តករបរធន-បាលកិច្ច" នៅសណ្ឋាគារ Rosewood Phnom Penh ក្នុងគោលដៅលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងជំរុញការចូលរួមអនុវត្តដល់សមាជិក-សមាជិការបស់សភាពាណិជ្ជកម្មម៉ាឡេស៊ីប្រចាំនៅកម្ពុជា ដែលជាស្ថាបនិក សហគ្រិន និងធុរជនមានសក្តានុពល និងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងសកម្មភាពធុរកិច្ចនៅប្រទេសកម្ពុជា ក្នុងគោលបំណងធ្វើយ៉ាងណាឱ្យសហគ្រិន និងធុរជនទាំងអស់អាចយល់បានពីយន្តការប្រតិបត្តិការបរធនបាលកិច្ច មានលទ្ធភាពសមស្របដើម្បីរៀបចំខ្លួនចូលរួមអនុវត្ត និងទាញយកផលប្រយោជន៍ពីប្រតិបត្តិការបរធនបាលកិច្ច ក្នុងដំណើរការធុរកិច្ចរបស់ខ្លួន ក៏ដូចជាចូលរួមជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា តាមរយៈការលើកកម្ពស់ការយល់ដឹង និងផ្សព្វផ្សាយជាសាធារណៈ។

## មាតិកា


- សិក្ខាសាលាស្តីពី "បទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ចនៅកម្ពុជា÷ ទស្សនទានពីនិយ័តករបរធនបាលកិច្ច" ទំព័រទី១
- កិច្ចប្រជុំសម្រាប់ការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ឆ្នាំ២០២៣ ទំព័រទី២
- កិច្ចប្រជុំស្តីពីសមិទ្ធផលការងារសម្រេចបានប្រចាំខែមេសា ឆ្នាំ២០២៣ ទំព័រទី៣
- បេសកកម្មអំពីប្រតិបត្តិការឥណទាន និងការរៀបចំផែនការអាជីវកម្មជាមួយសហគមន៍កសិកម្ម និងសហគ្រាសផលិត និងកែច្នៃផលិតផលកសិកម្ម ទំព័រទី៣
- ប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំ២០២៣ ជាមួយក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ទំព័រទី៤
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែឧសភា ឆ្នាំ២០២៣ ទំព័រទី៤
- កិច្ចពិភាក្សាការងាររវាង **ន.ប.ធ.** ជាមួយវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា (AIB) ទំព័រទី៤
- កិច្ចប្រជុំកម្រិតបច្ចេកទេសដើម្បីពិភាក្សាការងារលម្អិតពាក់ព័ន្ធនឹងយន្តការ និងប្រតិបត្តិការឥណទាននៃគម្រោង ទំព័រទី៥
- កិច្ចប្រជុំអន្តរក្រសួង- ស្ថាប័ន ស្តីពីការវាយតម្លៃកិច្ចសម្របសម្រួលផ្លូវច្បាប់ និងអត្ថគាហកៈ (វិស័យទី១៣) ទំព័រទី៥
- សិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលស្តីពី "គោលការណ៍ណែនាំប្រតិបត្តិការឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃនិងលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១" ទំព័រទី៦
- កម្មវិធីបឋកថាគតិយុត្ត លើប្រធានបទ "សារៈសំខាន់នៃវិស័យបរធនបាលកិច្ចនៅកម្ពុជា" ទំព័រទី៦
- ពិធីអនុស្សរណៈនៃការយោគយល់គ្នារវាង **ន.ប.ធ.** ជាមួយសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ទំព័រទី៦
- កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ទំព័រទី៨




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

កម្មវិធីសិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ប្រធាន/នាយកប្រតិបត្តិ ថ្នាក់ដឹកនាំក្រុមហ៊ុន ដែលជាសមាជិក-សមាជិការបស់សភាពាណិជ្ជកម្មម៉ាឡេស៊ីប្រចាំនៅកម្ពុជា ក្រុមហ៊ុនបរធនបាល និងបុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចផងដែរ។ កម្មវិធីត្រូវបានបញ្ចប់ទៅដោយភាពរលូន និងប្រកបដោយផ្លែផ្កា ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។




រូបភាពសិក្ខាសាលាស្តីពី "បទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ចនៅកម្ពុជា៖ ទស្សនទានពីនិយ័តករបរធនបាលកិច្ច"។

## កិច្ចប្រជុំសម្រាប់ការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ឆ្នាំ២០២៣

នាព្រឹកថ្ងៃពុធ ១៤កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណី សាកល** អគ្គនាយករងនៃ **ន.ប.ធ.** និង **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំសម្រាប់ការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ឆ្នាំ២០២៣ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ និងច្បាប់ទូទាត់ថវិកា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់-ដឹកនាំស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។




រូបភាពកិច្ចប្រជុំសម្រាប់ការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំស្តីពីសមិទ្ធផលការងារសម្រេចបានប្រចាំខែមេសា ឆ្នាំ២០២៣

នារសៀលថ្ងៃពុធ ១៤កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣ **ឯកឧត្តម ណឹ សាកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំស្តីពីសមិទ្ធផលការងារសម្រេចបានប្រចាំខែមេសា ឆ្នាំ២០២៣ របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីប្រធានស្តីទីនាយកដ្ឋាន, អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច។ នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយករង បានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានប្រចាំខែមេសា ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារបន្ត ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាពកិច្ចប្រជុំស្តីពីសមិទ្ធផលការងារសម្រេចបានប្រចាំខែមេសា ឆ្នាំ២០២៣ ដឹកនាំដោយ **ឯកឧត្តម ណឹ សាកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច ។

## បេសកកម្មអំពីប្រតិបត្តិការឥណទាន និងការរៀបចំផែនការអាជីវកម្មជាមួយសហគមន៍កសិកម្ម និងសហគ្រាសផលិត និងកែច្នៃផលិតផលកសិកម្ម

ចាប់ពីថ្ងៃអង្គារ ១៣កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣ ដល់ថ្ងៃសុក្រ ១រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣, ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាពទី១ (PIU1) **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ នៃ **ន.ប.ធ.** និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP សម្រាប់សមាសភាពទី១ (PIU1) បានដឹកនាំមន្ត្រីជំនាញ និងទីប្រឹក្សាជាតិ និងអន្តរជាតិសម្រាប់សមាសភាពទី១ (PIU1) ដោយមានការចូលរួមពីទីប្រឹក្សា និងមន្ត្រីតំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ សម្រាប់សមាសភាពទី២ (PIU2) បានចុះបេសកកម្មដើម្បីពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (PDAFF) សម្រាប់សមាសភាពទី២ (PIU2) និងស្ថាប័នហិរញ្ញវត្ថុដៃគូ (PFIs) អំពីប្រតិបត្តិការឥណទាន និងការរៀបចំផែនការអាជីវកម្មជាមួយសហគមន៍កសិកម្ម និងសហគ្រាសផលិត និងកែច្នៃផលិតផលកសិកម្ម ដែលមានសក្តានុពលរួមមាន៖ សហគមន៍កសិកម្មភ្នំសន្ទុកនៅខេត្តកំពង់ធំ,សហគ្រាសកសិ-ឧស្សាហកម្ម (agri-enterprises) ខេត្តកំពង់ធំ, និងក្រុមហ៊ុន សានតាណា អាហ្គ្រោប្រដាក់ (SANTANA) នៅខេត្តព្រះវិហារ ជាដើម។



រូបភាពបេសកកម្មដើម្បីពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (PDAFF)។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំ២០២៣ ជាមួយ ក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)

នារសៀលថ្ងៃសុក្រ ៨រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំ២០២៣ ជាមួយក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** និងដោយមានការចូលរួមពីតំណាងនិយ័តករពាក់ព័ន្ធក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។



រូបភាពកិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំ២០២៣ ជាមួយក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែឧសភា ឆ្នាំ២០២៣

នាព្រឹកថ្ងៃអង្គារ ១២រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែឧសភា ឆ្នាំ២០២៣ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាន នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច។

កិច្ចប្រជុំនេះ មានការចូលរួមពីលោក/កញ្ញាប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យនិងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។

នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែមេសា ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាពកិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែឧសភា ឆ្នាំ២០២៣ ដឹកនាំដោយ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ។

## កិច្ចពិភាក្សាការងាររវាង ន.ប.ធ. ជាមួយវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា (AIB)

កាលពីថ្ងៃពុធ ១៣រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយមន្ត្រីជំនាញជាន់ខ្ពស់ បានទទួលជួបពិភាក្សាការងារជាមួយវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា (AIB) តំណាងដោយ **លោក ហុង ហេមូលី** នាយករងនៃវិទ្យាស្ថាន AIB អមដោយសហការី ដើម្បីពិនិត្យលទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការក្នុងគោលដៅដើម្បីបង្កើនសមត្ថភាពនិងចំណេះដឹងបន្ថែម និងពង្រីកវិសាលភាពនៃការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា ឱ្យបានទៅដល់សិស្ស-និស្សិតនៃវិទ្យាស្ថាន AIB ក៏ដូចជានឹងផ្តល់ឱកាសអាទិភាពដល់មន្ត្រីនៃ **ន.ប.ធ.** ដែលមានបំណងបង្កើនសមត្ថភាព និងចំណេះដឹងបន្ថែម ជាពិសេសពាក់ព័ន្ធផ្នែកហិរញ្ញវត្ថុ នៅទីស្តីការ **ន.ប.ធ.**។



រូបភាពកិច្ចពិភាក្សាការងាររវាង **ន.ប.ធ.** ជាមួយវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា (AIB) ដឹកនាំដោយ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**)។

## កិច្ចប្រជុំកម្រិតបច្ចេកទេសដើម្បីពិភាក្សាការងារលម្អិតពាក់ព័ន្ធនឹងយន្តការ និងប្រតិបត្តិការឥណទាននៃគម្រោង

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៤រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោង ACSEP សម្រាប់សមាសភាគទី១ (PIU1) **លោក ប៉ូ សំអាង** ប្រធានផ្នែកប្រតិបត្តិការ បានដឹកនាំកិច្ចប្រជុំកម្រិតបច្ចេកទេសដើម្បីពិភាក្សាការងារលម្អិតពាក់ព័ន្ធនឹងយន្តការ និងប្រតិបត្តិការឥណទាននៃគម្រោង។ កិច្ចប្រជុំនេះមានការចូលរួមពីប្រធានផ្នែក និងមន្ត្រីជំនាញ ទីប្រឹក្សាជាតិ និងអន្តរជាតិរបស់គម្រោង ACSEP សម្រាប់សមាសភាគទី១ ក្រុមមន្ត្រីជំនាញ ADB ដឹកនាំដោយលោក**បណ្ឌិត Takeshi Ueda** និង ក្រុមមន្ត្រីជំនាញ MAFF-PMU ដឹកនាំដោយ **លោកបណ្ឌិត ស ចិត្រា** សម្រាប់សមាសភាគទី២ (PIU2)។



រូបភាពកិច្ចប្រជុំកម្រិតបច្ចេកទេសដើម្បីពិភាក្សាការងារលម្អិតពាក់ព័ន្ធនឹងយន្តការ និងប្រតិបត្តិការឥណទាននៃគម្រោង។

## កិច្ចប្រជុំអន្តរក្រសួង-ស្ថាប័ន ស្តីពីការវាយតម្លៃកិច្ចសម្របសម្រួលផ្លូវច្បាប់ និងអត្ថគាហកៈ (វិស័យទី១៣)

នាព្រឹកថ្ងៃសុក្រ ១៥រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **កញ្ញា ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច អមដោយមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំអន្តរក្រសួង-ស្ថាប័ន ស្តីពីការវាយតម្លៃកិច្ចសម្របសម្រួលផ្លូវច្បាប់ និងអត្ថគាហកៈ (វិស័យទី១៣) នៃអនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដឹកនាំដោយ **ឯកឧត្តម សុខ សុភ័ក្ត្រ** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ដោយមានការចូលរួមពីក្រុមការងារដែលជាតំណាងក្រសួងស្ថាប័នពាក់ព័ន្ធសំខាន់ៗ រួមមាន៖ អគ្គស្នងការដ្ឋាននគរបាលជាតិ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ, ក្រសួងយុត្តិធម៌, ព្រះរាជអាជ្ញា, ចៅក្រម, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា, និយ័តករធានារ៉ាប់រងកម្ពុជា, និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ, និយ័តករមូលបត្រកម្ពុជា, និយ័តករគណនេយ្យនិងសវនកម្ម និងនិយ័តករសន្តិសុខសង្គម។



រូបភាពកិច្ចប្រជុំអន្តរក្រសួង-ស្ថាប័ន ស្តីពីការវាយតម្លៃកិច្ចសម្របសម្រួលផ្លូវច្បាប់ និងអត្ថគាហកៈ (វិស័យទី១៣) ដឹកនាំដោយ **ឯកឧត្តម សុខ សុភ័ក្ត្រ** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## សិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលស្តីពី "គោលការណ៍ណែនាំប្រតិបត្តិការឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១"

នាព្រឹកថ្ងៃចន្ទ ៣កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្មសម្រាប់សមាសភាគទី១ (ACSEP PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**ក.ស.ហ.វ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលស្តីពី "គោលការណ៍ណែនាំប្រតិបត្តិការឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោង ACSEP PIU1 នៅអគារនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ក្រុមការងារនៃធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា ដែលជាស្ថាប័នហិរញ្ញវត្ថុដៃគូក្នុងគម្រោង ACSEP/PIU1 ព្រមទាំងមន្ត្រីបង្គោលនៃ ACSEP/PIU1 អំពីការធ្វើបច្ចុប្បន្នភាពលើឯកសារគោលការណ៍ប្រតិបត្តិការឥណទាន និងនីតិវិធីនៃប្រតិបត្តិការឥណទានរបស់គម្រោង។




រូបភាពសិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលស្តីពី "គោលការណ៍ណែនាំប្រតិបត្តិការឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១"។

## កម្មវិធីបឋកថាគតិយុត្ត លើប្រធានបទ "សារៈសំខាន់នៃវិស័យបរធនបាលកិច្ចនៅកម្ពុជា"

នារសៀលថ្ងៃសៅរ៍ ១កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ឆែម លាបហេង** ប្រធានការិយាល័យអធិការកិច្ច និងពង្រឹងការអនុវត្តច្បាប់ អមដោយមន្ត្រីជំនាញ បានអញ្ជើញចូលរួមធ្វើជាវាគ្មិនក្នុងកម្មវិធីបឋកថាគតិយុត្ត លើប្រធានបទ "សារៈសំខាន់នៃវិស័យបរធនបាលកិច្ចនៅកម្ពុជា" នៅសាកលវិទ្យាល័យអាស៊ីអឺរ៉ុប ដោយមានការចូលរួមពីតំណាងក្រុមហ៊ុនមេធាវីតម្រាច្បាប់ ថ្នាក់ដឹកនាំ សិស្ស និស្សិតនៃសាកលវិទ្យាល័យអាស៊ីអឺរ៉ុប។




រូបភាពកម្មវិធីបឋកថាគតិយុត្ត លើប្រធានបទ "សារៈសំខាន់នៃវិស័យបរធនបាលកិច្ចនៅកម្ពុជា"។

## ពិធីអនុស្សរណៈនៃការយោគយល់គ្នារវាង ន.ប.ធ. ជាមួយជាមួយសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

នាល្ងាចថ្ងៃសុក្រ ៧កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និយ័តករបរធនបាលកិច្ច តំណាងដោយ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

បានចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងជំរុញការចូលរួមក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ជាមួយសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា តំណាងដោយ **អ្នកឧកញ៉ា លី ហួរ** ប្រធានសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនសុី ភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

ក្នុងក្របខណ្ឌនៃការចុះអនុស្សរណៈនៃការយោគយល់គ្នានេះ ភាគីទាំងពីរនឹងបង្កើតកិច្ចសហប្រតិបត្តិការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងជំរុញការចូលរួមអនុវត្តដល់សមាជិក-សមាជិការបស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ដែលជាស្ថាបនិក សហគ្រិន និងធុរជនមានសក្តានុពល និងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងសកម្មភាពធុរកិច្ចក្នុងវិស័យអចលនទ្រព្យនៅប្រទេសកម្ពុជា ក្នុងគោលបំណងធ្វើយ៉ាងណាឱ្យសហគ្រិន និងធុរជនទាំងអស់អាចយល់បានពីយន្តការប្រតិបត្តិការបរធនបាលកិច្ច មានលទ្ធភាពសមស្របដើម្បីរៀបចំខ្លួនចូលរួមអនុវត្ត និងទាញយកផលប្រយោជនពីប្រតិបត្តិការបរធនបាលកិច្ច ក្នុងដំណើរការធុរកិច្ចរបស់ខ្លួន ក៏ដូចជា ចូលរួមជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា តាមរយៈការលើកកម្ពស់ការយល់ដឹង និងផ្សព្វផ្សាយជាសាធារណៈ។

ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នានេះ មានការអញ្ជើញចូលរួមពី **ឯកឧត្តម ឈុន សម្បត្តិ** ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** និងឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងឱ្យនិយ័តករទាំងអស់ក្រោមឱវាទរបស់ **អ.ស.ហ.** ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** អ្នកឧកញ៉ា លោកឧកញ៉ា លោកជំទាវឧកញ៉ា លោក លោកស្រី ជាអនុប្រធាន ជាសមាជិក-សមាជិកានៃសមាគមអ្នកអភិវឌ្ឍន៍លំនៅដ្ឋានកម្ពុជា តំណាងក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច និងបុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចផងដែរ។




រូបភាពពិធីអនុស្សរណៈនៃការយោគយល់គ្នារវាង **ន.ប.ធ.** ជាមួយជាមួយសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

# កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

នារសៀលថ្ងៃពុធ ១២កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាអនុប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ បានដឹកនាំសហការីចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងជាប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ តាមប្រព័ន្ធអនឡាញ Zoom។






រូបភាពកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងជាប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888